**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

លេខ: ១០២៥/១៥ សស.គគ

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ភ្នំពេញ, ថ្ងៃទី ០២ ខែ តុលា ឆ្នាំ២០១៥

# សេចក្តីសម្រេច

## ស្តីពីការកែសម្រួលតួនាទី ភារកិច្ច សិទ្ធិអំណាចរចនាសម្ព័ន្ធចាត់តាំង និងរបៀបរបបធ្វើការ របស់គណៈកម្មាធិការត្រួតពិនិត្យគណៈកម្មាធិការកណ្តាល

**យោង** : លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងគណបក្សប្រជាជនកម្ពុជា

- សេចក្តីកំណត់លេខ ០៤ ស.ស.រ.ម.ឈ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៨៦ របស់គណៈកម្មាធិការមជ្ឈិមបក្ស អំពីភារកិច្ច សិទ្ធិអំណាច និងអង្គការចាត់តាំង របស់គណៈកម្មាធិការត្រួតពិនិត្យមជ្ឈិមបក្ស។
- សភាពការណ៍ និងសំណូមពរនៃភារកិច្ចនយោបាយរបស់គណបក្ស ក្នុងដំណាក់កាលបច្ចុប្បន្ន។
- លិខិតរបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** អនុប្រធានគណបក្ស និងជាប្រធានគណៈប្រចាំការគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល និងចំណារយល់ព្រមរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្ស ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ២០១៥។
- ស្មារតីនៃអង្គប្រជុំ របស់គណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ២០១៥។

## គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល
## សម្រេច

<u>ប្រការ ១</u> : កែសម្រួលតួនាទី ភារកិច្ច សិទ្ធិអំណាច រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់គណៈកម្មាធិការត្រួតពិនិត្យគណៈកម្មាធិការកណ្តាល ដូចខាងក្រោម ៖

ក. <u>តួនាទី</u>

គណៈកម្មាធិការត្រួតពិនិត្យគណៈកម្មាធិការកណ្តាល ជាស្ថាប័នជំនួយការរបស់គណៈកម្មាធិការកណ្តាល មានតួនាទីត្រួតពិនិត្យការអនុវត្តលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយ សេចក្តីសម្រេចចិត្តនានារបស់គណបក្ស និងស្រាវជ្រាវ ត្រួតពិនិត្យចំពោះមន្ត្រីគណបក្ស និងអង្គការចាត់តាំងគណបក្ស ស្ថិតក្រោមការគ្រប់គ្រងរបស់ថ្នាក់កណ្តាល ដែលបានប្រព្រឹត្តល្មើសខុសឆ្គង។

ខ. ភារកិច្ច

១. តាមដាន និងជំរុញការដឹកនាំរបស់អង្គការចាត់តាំងគណបក្ស និងមន្ត្រីគណបក្ស ស្ថិតក្រោមការគ្រប់គ្រងរបស់ថ្នាក់កណ្តាល ក្នុងការអនុវត្តលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កម្មវិធីនយោបាយ គោលការណ៍ គោលនយោបាយ និងសេចក្តីសម្រេចចិត្តនានា របស់គណបក្ស ឲ្យសម្រេចបានជោគជ័យ។

២. ត្រួតពិនិត្យ អង្គការចាត់តាំងគណបក្ស និងមន្ត្រីគណបក្ស ស្ថិតក្រោមការគ្រប់គ្រងរបស់ថ្នាក់កណ្តាល ដែលបានប្រព្រឹត្តល្មើសលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងគណបក្ស វិន័យរបស់គណបក្ស ច្បាប់រដ្ឋ និងលក្ខណសម្បត្តិរបស់មន្ត្រី ឬ សមាជិកគណបក្ស។

៣. ទទួល និងដោះស្រាយ បណ្តឹងបរិហារ និងបណ្តឹងតវ៉ា ចំពោះអង្គការចាត់តាំងគណបក្ស ឬ មន្ត្រី សមាជិកគណបក្សនៅគ្រប់ថ្នាក់។

៤. តាមដាន ត្រួតពិនិត្យការដាក់វិន័យ និងការអនុវត្តវិន័យចំពោះមន្ត្រី ឬ សមាជិកគណបក្ស របស់អង្គការចាត់តាំងគណបក្សថ្នាក់ក្រោម។ .

៥. ត្រួតពិនិត្យហិរញ្ញវត្ថុរបស់គណបក្ស តាមការប្រគល់ភារកិច្ចរបស់គណៈប្រចាំការ ឬ គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល។

៦. ណែនាំគណៈកម្មាធិការត្រួតពិនិត្យគណបក្សថ្នាក់ក្រោម ឲ្យអនុវត្តបានត្រឹមត្រូវតាមតួនាទី ភារកិច្ច ត្រួតពិនិត្យរបស់ថ្នាក់ខ្លួន។

៧. សហការ ជាមួយគណៈចាត់តាំងគណៈកម្មាធិការកណ្តាល ក្នុងការស្នើសុំតែងតាំងមន្ត្រីគណៈកម្មាធិការត្រួតពិនិត្យ របស់គណៈកម្មាធិការគណបក្ស រាជធានី-ខេត្ត ក្រសួង-ស្ថាប័ន។

- សហការ ជាមួយបណ្តាស្ថាប័នគណបក្ស ជុំវិញគណៈកម្មាធិការកណ្តាល ដើម្បីសម្រេចឲ្យបានល្អនូវការងារត្រួតពិនិត្យរបស់គណបក្ស។

៨. ស្រាវជ្រាវ និងផ្លាស់ប្តូរបទពិសោធន៍ អំពីជំនាញនៃការងារត្រួតពិនិត្យរបស់គណបក្ស ទាំងនៅក្នុងប្រទេស និងក្រៅប្រទេស។

៩. ទទួលអនុវត្តភារកិច្ចពាក់ព័ន្ធដទៃទៀត ដែលគណៈប្រចាំការ ឬ គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលប្រគល់ជូន។

គ. សិទ្ធិអំណាច

- តាមដាន និងលើកមតិជូនថ្នាក់កណ្តាល ក្នុងការលើកសរសើរ អង្គការចាត់តាំងគណបក្ស ឬ មន្ត្រីគណបក្ស ស្ថិតក្រោមការគ្រប់គ្រងរបស់ថ្នាក់កណ្តាល ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចជូនគណបក្ស និងជាតិមាតុភូមិ។

- លើកមតិ ក្នុងការដាក់វិន័យ ចំពោះអង្គការចាត់តាំងគណបក្ស ឬ មន្ត្រីគណបក្ស ស្ថិតក្រោមការគ្រប់គ្រងរបស់ថ្នាក់កណ្តាលដែលល្មើសខុសឆ្គង ជូនថ្នាក់កណ្តាល ពិនិត្យ និងសម្រេច។

- លើកមតិ យល់ព្រមផ្លាស់ប្តូរ ឬ លុបសេចក្តីសម្រេច របស់អង្គការចាត់តាំងគណបក្សថ្នាក់ក្រោម ក្នុងការអនុវត្តការដាក់វិន័យ ចំពោះអង្គការចាត់តាំងគណបក្ស ឬ មន្ត្រី ឬ សមាជិកគណបក្សថ្នាក់ក្រោម ជូនថ្នាក់កណ្តាល ពិនិត្យ និងសម្រេច។

- ស្រាវជ្រាវ និងលើកមតិ ដើម្បីសុំផ្អាកការអនុវត្តគោលការណ៍ គោលនយោបាយ សេចក្តីសម្រេច ណាមួយរបស់គណបក្ស ដែលមិនសមស្រប ជូនថ្នាក់កណ្តាល ពិនិត្យ និងសម្រេច។

- ត្រួតពិនិត្យការងាររបស់គណៈកម្មាធិការត្រួតពិនិត្យថ្នាក់ក្រោម។

- សំណូមពរ ឲ្យអង្គការចាត់តាំងគណបក្សថ្នាក់ក្រោម បណ្តាស្ថាប័ន និងមន្ត្រី ឬ សមាជិកគណបក្ស ដែលពាក់ព័ន្ធ រាយការណ៍ ឬ ផ្តល់ឯកសារចាំបាច់ សម្រាប់ការងារត្រួតពិនិត្យ។

- ក្នុងករណីចាំបាច់ គណៈកម្មាធិការត្រួតពិនិត្យគណៈកម្មាធិការកណ្តាល អាចធ្វើរបាយការណ៍ជូនគណៈប្រចាំការ ឬ គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ដើម្បីស្នើសុំពិនិត្យ និងចេញសេចក្តីសម្រេចឲ្យផ្អាកជាបណ្តោះអាសន្ន ចំពោះអង្គការចាត់តាំងគណបក្សថ្នាក់ក្រោមណា ដែលបានប្រព្រឹត្តល្មើសនឹងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងគណបក្ស ឬ គាបសង្កត់ គំរាមកំហែងថ្នាក់ក្រោម ឬ ប៉ះពាល់ដល់ជីវិតនយោបាយ របស់មន្ត្រី ឬ សមាជិកគណបក្ស។

ឃ. រចនាសម្ព័ន្ធ

- គណៈកម្មាធិការត្រួតពិនិត្យ និងប្រធានគណៈកម្មាធិការត្រួតពិនិត្យនៃគណៈកម្មាធិការកណ្តាល អាស្រ័យដោយសន្និបាតពេញអង្គនៃគណៈកម្មាធិការកណ្តាល បោះឆ្នោតជ្រើសតាំងឡើង ( តាមមាត្រាទី ២២ ជំពូក VII នៃលក្ខន្តិកៈគណបក្ស )។

- គណៈកម្មាធិការត្រួតពិនិត្យនៃគណៈកម្មាធិការកណ្តាល រួមមាន ប្រធាន , អនុប្រធាន និងសមាជិកមួយចំនួន។

- គណៈកម្មាធិការត្រួតពិនិត្យគណៈកម្មាធិការកណ្តាល ត្រូវរៀបចំរចនាសម្ព័ន្ធចាត់តាំងឲ្យបានសមស្រប និងមានប្រសិទ្ធភាព ដើម្បីធានាអនុវត្តភារកិច្ច សិទ្ធិអំណាចរបស់ខ្លួន រួមមាន មន្ទីរ និងនាយកដ្ឋានមួយចំនួន។ ចំពោះមុខនេះ អាចរៀបចំឲ្យមានមន្ទីរមួយ និងនាយកដ្ឋានពីរ ដូចមានក្នុងឧបសម្ព័ន្ធភ្ជាប់មកជាមួយ។

- គណៈកម្មាធិការត្រួតពិនិត្យគណៈកម្មាធិការកណ្តាល អាចជ្រើសរើសមន្ត្រីក្របខ័ណ្ឌជំនួយការមួយចំនួន តាមការចាំបាច់នៃការងារ ស្របតាមការកំណត់របស់ គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល។

ង. របៀបរបបធ្វើការងារ

- គណៈកម្មាធិការត្រួតពិនិត្យគណៈកម្មាធិការកណ្តាល ធ្វើការងារក្រោមការដឹកនាំរបស់គណៈកម្មាធិការកណ្តាល គណៈអចិន្ត្រៃយ៍ និងគណៈប្រចាំការនៃគណៈកម្មាធិការកណ្តាល។

- គណៈកម្មាធិការត្រួតពិនិត្យគណៈកម្មាធិការកណ្តាល ធ្វើការតាមរបបសមូហភាព និងត្រូវសម្រេចតាមមតិភាគច្រើនដាច់ខាត នៃចំនួនសមាជិកគណៈកម្មាធិការត្រួតពិនិត្យគណៈកម្មាធិការកណ្តាលទាំងមូល។

- ប្រធាន និងអនុប្រធាន ទទួលភារកិច្ចដោះស្រាយការងារប្រចាំថ្ងៃ។

- គណៈកម្មាធិការត្រួតពិនិត្យគណៈកម្មាធិការកណ្តាល ត្រូវមានរបបប្រជុំឲ្យបានទៀងទាត់និងត្រូវរាយការណ៍អំពីសភាពការណ៍ និងសុំយោបល់ណែនាំពីគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ឬពីគណៈប្រចាំការគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ស្តីពីការងារត្រួតពិនិត្យតាមការចាំបាច់។

- ផ្អែកតាមសេចក្តីសម្រេចនេះ គណៈកម្មាធិការត្រួតពិនិត្យគណៈកម្មាធិការកណ្តាល ត្រូវលើកផែនការសកម្មភាព និងកសាងបទវិន័យផ្ទៃក្នុងរបស់ខ្លួន និងបណ្តោអង្គភាពជំនួយការ សំដៅធានាអនុវត្តឲ្យបានល្អនូវរាល់ភារកិច្ចដែលបានកំណត់។

- គណៈកម្មាធិការត្រួតពិនិត្យគណៈកម្មាធិការកណ្តាល ត្រូវបូកសរុប និងបញ្ចូលបញ្ហាសំខាន់ៗ នៃលទ្ធផលការងារត្រួតពិនិត្យរបស់គណបក្ស តាមរយៈកាលនីមួយៗ ទៅក្នុងរបាយការណ៍នយោបាយ សម្រាប់សន្និបាតគណៈកម្មាធិការកណ្តាល ឬ មហាសន្និបាតសាមញ្ញ ឬ វិសាមញ្ញគណៈទូទាំងប្រទេសរបស់គណបក្ស។

<u>ប្រការ២</u> ៖ សេចក្តីសម្រេច ឬ សេចក្តីកំណត់ពីមុន ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

<u>ប្រការ៣</u> ៖ ខុទ្ទកាល័យគណៈកម្មាធិការកណ្តាល គណៈចាត់តាំងគណៈកម្មាធិការកណ្តាល គណៈកម្មាធិការត្រួតពិនិត្យគណៈកម្មាធិការកណ្តាល ស្ថាប័នគណបក្ស និងមន្ត្រីគណបក្សដែលពាក់ព័ន្ធ ត្រូវប្រតិបត្តិតាមសេចក្តីសម្រេចនេះ៕

ជ.គណៈអចិន្ត្រៃយ៍
ប្រធាន

ហ៊ុន សែន

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វិឌ្ឍនភាពសង្គម

# ឧបសម្ព័ន្ធ

## ស្តីពីរចនាសម្ព័ន្ធចាត់តាំងរបស់ គណៈកម្មាធិការត្រួតពិនិត្យគណៈកម្មាធិការកណ្តាល




ភ្នំពេញ ថ្ងៃទី១០ ខែ កញ្ញា ឆ្នាំ ២០១៥
**ជ. គណៈអធិបតីរួមប្រធាន**
**ប្រធាន**

**ហ៊ុន សែន**